ភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣

# សេចក្តីសំរេច លេខ ០៨ សសរ

*********

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់សម្តេចព្រះប្រមុខរដ្ឋ ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៣ តែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា
- ដោយមានការចាំបាច់ក្នុងការងាររដ្ឋាភិបាល

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មាធិការជាតិសំរាប់និតិសម្បទា និង អភិវឌ្ឍន៍ ( ហៅកាត់ថា គជនា ) នៃប្រទេសកម្ពុជា ។

ប្រការ ២ : គជនា មានភារកិច្ចសំរបសំរួលការងាររបស់ក្រសួង និងស្ថាប័ននានា ដែលមានសមត្ថកិច្ចនិងការពាក់ព័ន្ធក្នុងការលើកផែនការកម្មវិធី និង គំរោងក្នុងការទទួលជំនួយបរទេស និង ក្នុងការធ្វើវិនិយោគ ទាំងសាធារណៈ ទាំងឯកជនសំរាប់ស្តារនិងកសាងប្រទេស ។ ភារកិច្ចសំរបសំរួលការងារនេះសំដៅសំខាន់ ÷

ទី ១ : លើកលំដាប់អាទិភាពនៃតម្រូវការនៃប្រទេសក្នុងការធ្វើនីតិសម្បទា និងអភិវឌ្ឍន៍នៅក្នុងពេលបច្ចុប្បន្នជាបន្ទាន់ និងទៅអនាគតជាខ្សែសង្វាក់ ។

ទី២ : ញ៉ាំងអោយកម្មវិធីនីតិសម្បទា និងអភិវឌ្ឍន៍ ជាប្រព័ន្ធខ្សែសង្វាក់ រលូន និងប្រទាក់ក្រឡាគ្នា ។ រាល់គំរោងត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីនេះ ។

ទី ៣ : តម្រង់ទិសក្នុងការបែងចែក និងការផ្គត់ផ្គង់ធនធានក្នុងប្រទេស និងដែលបានមកពីក្រៅប្រទេស ដើម្បីនីតិសម្បទា និងអភិវឌ្ឍន៍ប្រទេស ។ ជាក់ស្តែង សំរប សំរួលការទទួលជំនួយ ទ្វេភាគី ពហុភាគី និងអន្តរជាតិ អោយសមស្រប អាទិភាពនៃតម្រូវការ ហើយសំរបសំរួលការទទួល ជំនួយនេះ ជាមួយនឹងកិច្ចការវិនិយោគ ។ គជនា នឹងតាមដានក្នុងវិចារណញាណបរិយកម្ម និង ប្រសិទ្ធភាពនៃការបែងចែក និងការផ្គត់ផ្គង់នៃធនធាន ។

ប្រការ ៣ : សមត្ថកិច្ចរបស់ គជនា ត្របដណ្តប់ផ្នែកដូចតទៅ ÷

ទី ១ : ការស្តារ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ជារូបវត្ថុទាំងឡាយសំរាប់ ចំរើនផលិតកម្មកសិកម្ម និងឧស្សាហកម្ម ការដឹកជញ្ជូន សេវាកម្មនានា ព្រមទាំង សុខមាលភាព

ទី ២ : ការធ្វើនិតិសម្បទា និងអភិវឌ្ឍន៍ធនធានមនុស្ស ។ ក្នុងនេះទន្ទឹមនឹង ការបំប៉នសុខភាព ពង្រីកចំណេះដឹង ចំណេះធ្វើផងនា យកចិត្តទុកដាក់ដល់ការផ្លាស់ប្តូរឥរិយាបថ អោយសមស្របតាមយន្តការទីផ្សារក្នុងក្របខ័ណ្ឌ នៃ គោលការណ៍ ដែលញាំងអោយការធ្វើនិតិសម្បទា និង អភិវឌ្ឍន៍ធនធានមនុស្ស នេះជាកម្លាំងចលករផង និង ជាគោលដៅផង ។

ទី ៣ : ការកែប្រែរចនាសម្ព័ន្ធរដ្ឋបាល និង ក្រសួងនានា និងការធ្វើ ឬ កែលំអលិខិតបទដ្ឋានដែលត្រូវសំដៅបំពេញកិច្ចការពារប្រទេស សន្តិសុខ និងសុខមាលភាពរបស់ប្រជារាស្ត្រ និងសំដៅបំរើយន្តការទីផ្សារ ដោយរដ្ឋ និង ឯកជន ត្រូវប្រកាន់តួនាទីជាដៃគូនឹងគ្នា និងគួសន្ទនាហើយក្នុងនេះរដ្ឋត្រូវស្ថិតជាយុទ្ធសាស្ត្រវិទូនៃការអភិវឌ្ឍន៍ ។

ទី ៤ : ការអភិវឌ្ឍន៍ធនធានធម្មជាតិ និងការការពារបរិដ្ឋាន ។ ក្នុងការងារនេះ បើទៅអនាគតសង្គមជាតិត្រូវបង់ថ្លៃធ្ងន់ជាងការប្រមូលចំណេញចំពោះមុខ ឧត្តមភាពនៃ ការងារជំពូកនេះ ត្រូវស្ថិតនៅលើការការពារបរិដ្ឋាន ។

ទី ៥ : ការពង្រឹង និងពង្រីកវាល់គ្រប់សកម្មភាពទ្រទ្រង់ និងសេវាកម្ម ដែលទ្រទ្រង់រាល់សកម្មភាពផលិតកម្ម និង ដែលបំរើសុខមាលភាពរបស់ប្រជារាស្ត្រ ។

ប្រការ ៤ : សមាសភាពនៃ គជនា មានដូចតទៅ ÷

១ - ឯកឧត្តម សាគ ឈន់ ឧបនាយករដ្ឋមន្ត្រី ជាសហប្រធាន

២ - ឯកឧត្តម ស៊ុខ ផន ឧបនាយករដ្ឋមន្ត្រី ជាសហប្រធាន

៣ - ព្រះអង្គម្ចាស់ នរោត្តម សិរីវុឌ្ឍ រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការ ជាសមាជិក

៤ - ឯកឧត្តម ជា ចាន់តូ រដ្ឋមន្ត្រីផែនការ ជាសមាជិក

៥ - ឯកឧត្តម សម រង្ស៊ី រដ្ឋមន្ត្រីហិរញ្ញវត្ថុ ជាសមាជិក

៦ - លោកស្រី ស៊ិន សិរី ទីប្រឹក្សាឯកឧត្តម រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាលេខាធិការ

៧ - លោកស្រី ច័ន្ទ សុរិយ៍ អនុប្រធាននាយកដ្ឋានពាណិជ្ជកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាជំនួយលេខាធិការ

ប្រការ ៥ : សហប្រធាននៃ គជនា និង អញ្ជើញរដ្ឋមន្ត្រីនៃក្រសួងនានាអោយចូលរួមក្នុងកិច្ចការ នៃ គជនា នេះតាមករណីដែលមានការពាក់ព័ន្ធ ។

ប្រការ ៦ : សហប្រធាននៃ គជនា កោះប្រជុំគណៈកម្មាធិការនេះតាមរយៈពេលទៀងទាត់ ។

ប្រការ ៧ : គជនា និង រាយការណ៍តាមកាលកំណត់ជូនគណៈរដ្ឋមន្ត្រី ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា　　　　　　ហត្ថលេខា

ព្រះអង្គស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ　　　　ហ៊ុន សែន

* * *

ភ្នំពេញ , ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ ០៩ សសរ

## ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ

## បរិស្ថាន និង ការរត់ពន្ធ

* * * *

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ នៃ កម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣

- យោងសំណូមពរការងារ ចាំបាច់

### សំរេច

ប្រការ ១ : បង្កើតគណៈកម្មការត្រួតពិនិត្យ បរិស្ថាន និង ការរត់ពន្ធ នៅក្រុងព្រះ សីហនុ និង ខេត្ត កោះកុងដែលមានសមាសភាពដូចតទៅ ÷

១- ឯកឧត្តម តាច សេងហួរ អនុរដ្ឋមន្ត្រីក្រសួង បរិស្ថាន　　ជាប្រធាន